YOUTH SERVICES

# សេវាកម្មសំរាប់យុវវ័យ

**តើលោកអ្នកត្រូវការជំនួយដើម្បីទទួលបាន GED របស់លោកអ្នកឬទេ ?**

**តើលោកអ្នកមានចំណាប់អារម្មណ៍ធ្វើការងារគំរោងដែលផ្តល់អត្ថប្រយោជន៏ដល់សហគមន៏ឬទេ ?**

**តើលោកអ្នកមានបំណងសិក្សាជំនាញដែលអាចអោយលោកអ្នកក្លាយជា ស្ថាបត្យករ អ្នកសរសេរអត្ថបទទាក់ទិននឹង វិស័យកីឡា ឬវិជ្ជាជីវៈដទៃទៀតឬទេ ?**

ប្រសិនបើលោកអ្នកឆ្លើយថា បាទ/ចាស់ ចំពោះសំណួរណាមួយក្នុងចំណោមសំណួរទាំងនេះ CTI អាចជួយលោក អ្នកបាន ។

YouthBuild - ជាកម្មវិធីបណ្តុះបណ្តាលការងារ និងជាកម្មវិធីសិក្សា សំរាប់យុវជន-យុវនារីវ័យក្មេងដែលឈប់រៀន ហើយត្រូវការ GED ។ YouthBuild ផ្តល់សេវាកម្មលើវិស័យអប់រំដល់យុវជន ដែលត្រូវការជំនួយ GED រួមមាន ជំនាញកុំព្យូទ័រជាមូលដ្ឋាន ចំណេះដឹងខាងហិរញ្ញវត្ថុ ជំនាញសហគ្រិន និងវគ្គបណ្តុះបណ្តាលលើការដឹកនាំ ។ សិស្សក៏អាច សិក្សាពីជំនាញសាងសង់ និងធ្វើការលើគំរោងសាងសង់ដែលជួយបង្កើនការផ្គត់ផ្គង់ផ្ទះ ដែលអាចអោយគេមានលទ្ធភាព ទិញបានផងដែរ ។ នេះជាកម្មវិធីពេញម៉ោង ដែលមានរយៈពេលប្រាំបួនខែ ដែលត្រូវបំពេញប្រចាំថ្ងៃ (ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ) ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៣:០០ រសៀល ចាប់ផ្តើមនៅខែកញ្ញា ។ សិស្សានុសិស្ស នឹងទទួលបានប្រាក់ បំណាច់ ខណៈដែលពួកគេជាសិស្សសកម្មក្នុងកម្មវិធីនេះ ។

**លក្ខខណ្ឌតំរូវ** : វគ្គបង្រៀនភាគច្រើន គឺសំរាប់ប្រជាពលនៅក្រុងឡូវែល ដែលមានអាយុ ១៧ ដល់ ២៤ ឆ្នាំ ដែលត្រូវនឹង លក្ខខណ្ឌរបស់សេចក្តីណែនាំស្តីពីប្រាក់ចំណូលទាបរបស់សហព័ន្ធ ។ វគ្គបង្រៀនខ្លះ អាចមានសំរាប់បុគ្គលដែលបំពេញមិន បានតាមលក្ខខណ្ឌតំរូវខាងលើ ។ ទំនាក់ទំនងទូរសព្ទ័លេខ ៩៧៨-៤៤៦-៩៨០៣ សំរាប់ព័តិមានបន្ថែម ។

**Spindle City Corps** - នេះជាកម្មវិធីរកការងារធ្វើ និងជាកម្មវិធីសិក្សាសំរាប់យុវវ័យនៅឡូវែល ។ កម្មវិធីនេះ ផ្តល់ឱកាសដល់យុវជន ដែលមានប្រភពសេដ្ឋកិច្ចនិងវប្បធមិចំរុះ អោយធ្វើការលើគំរោងរួមគ្នា ដែលផ្តល់អត្ថប្រយោជន៏ ដល់សហគមន៏ ។ អ្នកចូលរួមនឹងទទួលបានប្រាក់កំរៃ និងមានសិទ្ធទទួលបានអាហារូបករណ៏បន្ទាប់ពីបញ្ចប់កម្មវិធីនេះ ។ កម្មវិធីនេះចាប់ផ្តើមនៅចុងខែមិថុនា និងបន្តដល់ខែសីហា ។

**លក្ខខណ្ឌតំរូវ** : បេក្ខជននានាត្រូវបានចូលរៀន វិទ្យាល័យនៅថ្នាក់ខ្ពស់ ឬទាប ឬបានចុះឈ្មោះនៅមហាវិទ្យាល័យ ឬចុះ ឈ្មោះក្នុងកម្មវិធី GED និងមានអាយុក្រោម ២១ ឆ្នាំ ។
ទំនាក់ទំនងទូរសទព្ទ័លេខ ៩៧៨-៦៥៤-៥០៨០ សំរាប់ព័តិមានបន្ថែម ។

**កម្មវិធីសាលារៀនសំរាប់ប្រជាពលរដ្ឋ** - កម្មវិធីនេះត្រូវបានផ្តល់នៅឯសាលាចំនួនពីរ គឺសាលា Wang និងសាលា Robinson ហើយមានទិសដៅចំពោះយុវជននៅក្នុងទីក្រុងសំរាប់សាលាអនុវិទ្យាល័យ ។ កម្មវិធីនេះប្រើវិធីសាស្រ្ត បែបបង្រៀនកូនជាង ដែលអាចអោយសិស្សមានលទ្ធភាពទទួលបានជំនាញវិជ្ជាជីវៈ ការអភិវឌ្ឍលើមុខជំនាញនានា និង ការយល់ដឹងពីសហគមន៏ក្នុងពេលដែលបង្កើនការសិក្សានៅក្នុងថ្នាក់ និងជំនាញធ្វើកិច្ចការសាលា ។ យើងផ្តល់ការគាំទ្រ ផ្នែកកិច្ចការសាលារយៈពេលមួយម៉ោងក្នុងមួយថ្ងៃ ។ សិស្សអាចជ្រើសរើសយកវគ្គបែបបង្ហាត់បង្រៀនកូនជាងមួយក្នុង ចំណោមវគ្គបង្ហាត់បង្រៀនចំនួនប្រហែលប្រាំពីរ (៧) ដែលផ្តល់ជូន ។

**លក្ខខណ្ឌតំរូវ** : សំរាប់សិស្សអនុវិទ្យាល័យរបស់សាលា Wang ឬសាលា Robinson នឹងត្រូវចូលរៀន ៣ ម៉ោងក្នុង មួយថ្ងៃ បន្ទាប់ពីម៉ោងសិក្សារហូតដល់ម៉ោង ៥:៣០ ល្ងាច ។ ថ្នាក់បង្រៀនបែបបង្ហាត់កូនជាង មានរយៈពេល ១០ សប្តាហ៏ និងមានបទបង្ហាញជាសាធារណៈ ។ មិនមានការអោយចំណាត់ថ្នាក់ទេ ។ ទំនាក់ទំនងទូរសព្ទ័លេខ ៩៧៨-៦៥៤-៥០៨០ និងលេខភ្ជាប់ ២១ សំរាប់ព័តិមានបន្ថែម ។